# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦

**ជប៉ុនផ្តល់ថវិកាចំនួន ៨៣៣,៣៣២ដុល្លាអាមេរិក**
**សម្រាប់គម្រោងបង្កើនសមត្ថភាពបោសសម្អាតមីនដល់CMAC (ដំណាក់កាលទី៣)**

ក្រោមគ្រោងការណ៍នៃជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន ៨៣៣,៣៣២ដុល្លាអាមេរិក ដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)។ កិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះ ត្រូវបានចុះហត្ថលេខាដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ស៊ីបាតា មិគីអុ ប្រធានតំណាងអង្គការJMAS ដើម្បីអនុវត្ត "គម្រោងបង្កើនសមត្ថភាពបោសសម្អាតមីនដល់CMAC (ដំណាក់កាលទី៣)" នៅស្ថានទូតជប៉ុន។

នៅក្នុងគម្រោងនេះ អង្គការJMAS នៅតែបន្តការបណ្តុះបណ្តាលដល់កងអនុសេនាតូចបោសសម្អាតមីនរបស់CMAC ដោយធ្វើការអនុវត្តនូវកម្មវិធីសិក្សាមួយដែលមានឈ្មោះថា "កម្មវិធីសិក្សាបោសសម្អាតមីនរួមបញ្ចូលគ្នា" ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំទី១នៃគម្រោងនេះ ដើម្បីផ្ទេរនូវបច្ចេកទេសជំនាញផ្នែកបោសសម្អាតមីនប្រកបដោយប្រសិទ្ធិភាពដោយរួមបញ្ចូលការប្រើប្រាស់រវាងកំលាំងមនុស្ស និងម៉ាស៊ីនដល់CMAC។ កម្មវិធីសិក្សានេះរួមមានៈ ការបណ្តុះបណ្តាលអនុវត្តជាក់ស្តែងនៅក្នុងចំការមីនប្រមាណជា២៦០ហិចតា ក្នុងឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋប្រមាណជា ១,៧០០នាក់ ដោយកាត់បន្ថយនូវការគំរាមគំហែងពីគ្រាប់មីន និងសម្រួលដល់ការអភិវឌ្ឍសហគមន៍ក្នុងតំបន់គោលដៅនេះផងដែរ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តារនីតិសម្បទាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង២៦.២លានដុល្លាអាមេរិក ដល់គម្រោងចំនួន៩៥ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីន។ គម្រោងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ គឺជាគម្រោងទី៣ តាមរយៈគ្រោងការណ៍នៃជំនួយនេះនៅប្រទេសកម្ពុជាសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៦របស់ជប៉ុន (មេសា២០១៦ ដល់មិនា២០១៧)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល:* eco.jpn@.pp.mofa.go.jp
*គេហទំព័រផ្លូវការ:* www.kh.emb-japan.go.jp